**សុន្ទរកថារបស់ លោក ហូជីម៉ុតូ តូស៊ីគី**
**លេខាទី២ ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់ជាផ្លូវការនូវ**
**មជ្ឈមណ្ឌលសហគមន៍កសិកម្ម ក្នុងខេត្តស្ទឹងត្រែង**
**ថ្ងៃទី ២៥ ខែឧសភា ២០១៧**

- សូមគោរព **ឯកឧត្តម ម៉ុម សារឿន** អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង
- សូមគោរព **លោក លៀង សេង** ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង
- សូមគោរព **លោក ថោង ស្រាន់** អភិបាលស្រុកថាឡាបរីវ៉ាត់
- សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានមកចូលរួមក្នុងពិធីសម្ពោធនៅឃុំព្រះរំកិល ស្រុកថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ុម សារឿន** អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ដើម្បីប្រារព្វពិធីសម្ពោធមជ្ឈមណ្ឌលសហគមន៍កសិកម្មទាំងបីនេះ។

កសិកម្ម គឺជាវិស័យដ៏មានសារៈសំខាន់នៃបណ្តាវិស័យដទៃទៀតនៅក្នុងប្រទេសកម្ពុជា ដែលបានរួមចំណែកដល់ចំណូលប្រជាជនប្រមាណជា ៣០% ដោយសារតែជាងពាក់កណ្តាលនៃដង់ស៊ីតេប្រជាជនជាកសិករ។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃវិស័យកសិកម្មសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចនៅប្រទេសកម្ពុជា រដ្ឋាភិបាលជប៉ុន បាននឹងកំពុងជួយគាំទ្រនូវកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈយន្តការជាច្រើនដែលក្នុងនោះរួមមាន៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់ជំនួយផ្នែកបច្ចេកទេសជាដើម។

ជំនួយឧបត្ថម្ភឥតសំណងរបស់ជប៉ុនទាំងអស់នេះ គឺអនុលោមតាមគោលនយោបាលរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះរួមមាន៖ គោលនយោបាលអភិវឌ្ឍផ្នែកឧស្សាហកម្ម ក្នុងការលើកស្ទួយការនាំចេញអង្ករ ពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការបូកបន្ថែមនូវតម្លៃផលិតផលកសិកម្ម តាមរយៈការលើកស្ទួយផលិតកម្មស្បៀងអាហារ និងការគ្រប់គ្រងអោយបានត្រឹមត្រូវក្រោយពេលប្រមូលកសិផលជាដើម។

ក្រោមការដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហគមន៍កសិកម្មប្រមាណជា៨៥០ ត្រូវបានបង្កើតឡើងនៅទូទាំងប្រទេសកម្ពុជា ហើយកសិករទាំងអស់ កំពុងតែព្យាយាមកែលម្អជីវភាពរស់នៅ តាមរយៈការប្រកបមុខរបរអាជីវកម្មរបស់ពួកគេ ប៉ុន្តែពួកគេនៅតែជួបផលលំបាកជាច្រើនផងដែរ។ ខ្ញុំបានទទួលដំណឹងថា កសិករនៅក្នុងខេត្តស្ទឹងត្រែងនេះ ជួបផលលំបាកជាច្រើនក្នុងការលក់ផលិផលកសិកម្មក្នុងតម្លៃមួយសមរម្យ ដោយសារតែកង្វះខាតមិនត្រឹមតែម៉ាស៊ីនកសិកម្មប៉ុណ្ណោះទេ ថែមទាំងកង្វះខាតនូវឃ្លាំងស្តុកកសិផល និងឧបករណ៍ផលិតកម្មមួយចំនួនផងដែរ។

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយដែលបានមកឃើញមជ្ឈមណ្ឌលសហគមន៍កសិកម្មថ្មីទាំងនេះ ត្រូវបានសាងសង់ឡើងក្រោយជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។ មជ្ឈមណ្ឌលសហគមន៍កសិកម្មចំនួន៣ និងម៉ាស៊ីនកសិកម្មមួយចំនួនរួមមាន៖ គោយន្តកន្ត្រៃចំនួន ០៣គ្រឿង ម៉ាស៊ីនបោកស្រូវចំនួន ០២គ្រឿង ម៉ាស៊ីនកិនដំឡូងមីចំនួន ០២គ្រឿង និងឡសម្ងួតស្រូវចំនួន ០១កន្លែង ក៏ត្រូវបានសាងសង់ និងផ្តល់ជូនដល់សហគមន៍កសិកម្មចំនួន ៣ ដែលក្នុងនោះរួមមាន៖ សហគមន៍កសិកម្មព្រះរំកិល និងសហគមន៍កសិកម្មរាំសារស្ទឹងត្រែង ក្នុងស្រុកថាឡាបរីវ៉ាត់ និងសហគមន៍កសិកម្មអ៊ុំឃ្លូងរុងរឿង ក្នុងស្រុកសៀមបូក។

ឥឡូវនេះ ខ្ញុំសូមធ្វើការលើកឡើងនូវទស្សនៈពីរនៃប៉ះពាល់ជាវិជ្ជមានរបស់គម្រោងជំនួយនេះ និងសំណូមពរមួយ។ ទស្សនៈទី១ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ការនាំចេញអង្ករបស់កម្ពុជា មានការកើនឡើងដែលត្រូវបានចាត់ទុកថាជាអង្ករដែលមានគុណភាពខ្ពស់លើពិភពលោក។ ក្រៅពីអង្ករ ប្រទេសកម្ពុជា ក៏មានលទ្ធភាពក្នុងការដាំបន្លែនានាផងដែរ។ ខ្ញុំជឿជាក់ថា ការផ្តល់ជំនួយឧបត្ថម្ភនៅថ្ងៃនេះ នឹងជួយបង្កើនការផលិតកសិផលដែលមានគុណភាពខ្ពស់បន្ថែមទៀត។

ទស្សនៈទីពីរ ខ្ញុំសង្ឃឹមថា កសិករកាន់តែច្រើន នឹងអាចបង្កើនប្រាក់ចំណូល និងគុណភាពនៃជីវិតរបស់ពួកគេកាន់តែល្អប្រសើរជាងមុន តាមរយៈការលក់ផលិផលរបស់ពួកគេក្នុងតំលៃខ្ពស់ជាងមុន និងកាត់បន្ថយនូវការចំណាយថ្លៃដើម ដែលអាចអោយអតិថិជនកាន់តែច្រើនទទួលបាននូវផលិផលកម្ពុជាដែលមានគុណភាពល្អ។

ជាទីបញ្ចប់ ខ្ញុំសំណូមពរដល់កសិករទាំងអស់ ជួយថែទាំ និងជួសជុលមជ្ឈមណ្ឌលសហគមន៍កសិកម្ម និងម៉ាស៊ីនកសិកម្មទាំងអស់នេះអោយបានត្រឹមត្រូវគង់វង្សល្អ ដើម្បីទុកជានិមិត្តរូបដ៏យូរអង្វែងនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

មុននឹងបញ្ចប់នូវសុន្ទរកថារបស់ខ្ញុំ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកក្នុងការអនុវត្តនូវគម្រោងនេះអោយបានបញ្ចប់ទៅដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**